ភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ( Agreement Between the Royal Government of Cambodia and the Government of His Majesty the Sultan and Yang Di-Pertuan of Brunei Darussalam for the Avoidance of Double Taxation and the Prevention of Fiscal Evasion with Respect to Taxes on Income-DTA )



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជាប្រថា នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡឹម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តមបណ្ឌិត សភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

និងឯកឧត្តម **ម៉ិនទីរ៉ាន់ ភាសមៀរហាន់ ពិន ម៉ិនទីរ៉ាន់ ហាជី មូហាំម៉ាត់ តាហៀរ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសប្រ៊ុយណេដារូសាឡឹមប្រចាំ ព្រះរាជាណាចក្រកម្ពុជា តំណាងរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡឹម។

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងទី៣ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា ជាមួយប្រទេសដៃគូ បន្ទាប់ពីរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។ កិច្ចព្រមព្រៀងនេះ ផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាហត្ថលេខី លើកិច្ចការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ធ្វើឱ្យប្រាកដប្រជាក្នុងការកំណត់សិទ្ធិ នៃការយកពន្ធកំណើនមូលដ្ឋាន គិតពន្ធតាមរយៈការទាក់ទាញវិនិយោគដោយផ្ទាល់លំហូរមូលធន ការផ្ទេរបច្ចេកវិទ្យា និងជំនាញពីបរទេសការការពារនិវាសនជន ពីប្រព្រឹត្តកម្មមិនត្រឹមត្រូវពាក់ព័ន្ធនឹងពន្ធ និងការការពារចំណូលពន្ធ ក្នុងស្រុកតាមរយៈកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការគេចវេះពន្ធ រវាងប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅពេលដែលប្រទេសទាំងពីរបានបញ្ចប់នីតិវិធីក្នុងស្រុករៀងៗខ្លួន។


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

កិច្ចព្រមព្រៀងនេះគឺជាសមិទ្ធផលថ្មីមួយទៀតក្នុងចំណោមសមិទ្ធផលសំខាន់ៗជាច្រើនដែលរាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាន ជាពិសេសក្នុងបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើការចរចាលើកិច្ចព្រមព្រៀង ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគីបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ជាមួយបណ្តាប្រទេសដៃគូមួយចំនួនទៀតដូចជា វៀតណាម ថៃ ម៉ាឡេស៊ី កូរ៉េ ជាដើម៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ